សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការទៅមើលកុន
អញ្ចឹងជាទូទៅពួកយើងតែងតែទៅមើលកុននៅថ្ងៃណាដែលយើងឈប់សម្រាក
ឬថ្ងៃណាដែលយើងទំនេរ ដូចជាថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ដែលជាថ្ងៃដែលយើងមិនធ្វើការ
ឬក៏យើងមិនទៅសាលានោះទេ អញ្ចឹងពេលខ្លះយើងអាចបបួលមិត្តភក្តិរបស់យើងទៅមើលកុន
ឬក៏មើលភាពយន្តបាន អញ្ចឹងនៅពេលដែលយើងទៅមើលភាពយន្ត ឬក៏ទៅមើលរឿង
នៅក្នុងរោងកុន យើងហៅថាទៅមើលកុនក៏បាន ទៅមើលភាពយន្តក៏បាន

ដូច្នេះយើងក្រឡេកមកមើលរូបភាពទី ១ ទាំងអស់គ្នា ដោយនៅក្នុងរូបភាពទី ១
យើងឃើញមាននារីម្នាក់ បាទ ដែលនារីនោះ គាត់មានអាយុប្រហែលជា ២៥ ឆ្នាំ
គាត់កំពុងតែនៅអង្គុយនៅលើកៅអី អញ្ចឹងគាត់អង្គុយនៅលើកៅអីមួយ គាត់ចងសក់បួងទៅក្រោយ
គាត់ចងសក់បួងទៅក្រោយ ហើយគាត់ពាក់អាវដៃខ្លីពណ៌ខៀវ ហើយអាវរបស់គាត់នោះគឺរៀលក
បានន័យថាអត់មានកទេ អញ្ចឹងអាវរបស់គាត់មានតែស្មាតែប៉ុណ្ណោះ
អញ្ចឹងគាត់កំពុងតែអង្គុយលើកៅអី ហើយគាត់កំពុងតែអង្គុយចុចកុំព្យូទ័រ
អញ្ចឹងនៅខាងមុខគាត់គឺមានតុមួយ ហើយគាត់ដាក់កុំព្យូទ័រ ឬក៏កុំព្យូទ័រយួរដៃ នៅលើតុនោះ
ដែលយើងឃើញថាគាត់កំពុងតែសរសេរសារទៅមិត្តភក្តិរបស់គាត់
ឬក៏គាត់កំពុងតែឆាតទៅមិត្តភក្តិរបស់គាត់ ដែលយើងឃើញនៅក្នុងនេះ
គឺគាត់បបួលមិត្តភក្តិរបស់គាត់ទៅមើលកុន ឬក៏មើលភាពយន្តនៅរោងភាពយន្ត
អញ្ចឹងយើងអាចហៅបានពីរ ទៅមើលកុន ឬក៏មើលភាពយន្ត ដែលកន្លែងបញ្ចាំងកុន
ឬកន្លែងបញ្ចាំងភាពយន្តនោះ យើងហៅថារោងកុន ឬក៏រោងភាពយន្ត ដែលនៅក្នុងនេះ
យើងឃើញថា គាត់កំពុងតែឆាតទៅមិត្តភក្តិរបស់គាត់ ដោយយើងគាត់សរសេរសារ
ដែលជាទូទៅនៅប្រទេសកម្ពុជាយើងចូលចិត្តលេងសារតាមរយៈហ្វេសប៊ុក ឬក៏ឡាញ
ឬក៏មានកម្មវិធីមួយចំនួនទៀត ដូចជាវីឆាតជាដើម
អញ្ចឹងយើងអាចផ្ញើសារទៅកាន់មិត្តភក្តិរបស់យើង ទៅកាន់មនុស្សដែលយើងស្រឡាញ់
ឬក៏ទៅកាន់ក្រុមគ្រួសាររបស់យើងតាមរយៈកម្មវិធីទាំងនោះ
ហើយជាទូទៅនៅកម្ពុជាយើងចូលចិត្តលេងតាមឡាញ និងលេងតាមហ្វេសប៊ុកជាដើម
អញ្ចឹងនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែលេងឆាតទៅកាន់មិត្តភក្តិរបស់គាត់
ដើម្បីបបួលមិត្តភក្តិរបស់គាត់ទៅមើលកុន។

ចូលមកដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីគាត់បានសរសេរសារ
ឬក៏ឆាតទៅកាន់មិត្តភក្តិរបស់គាត់ហើយ គាត់ក៏បានជិះម៉ូតូ អញ្ចឹងគាត់ក៏បានចេញពីផ្ទះរបស់គាត់
បានន័យថាគាត់ឈប់លេងកុំព្យូទ័រហើយ ហើយគាត់ក៏បានចេញពីផ្ទះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយកម៉ូតូរបស់គាត់ជិះទៅខាងក្រៅ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា ម៉ូតូរបស់គាត់
គឺមានពណ៌ផ្កាឈូក ម៉ូតូគឺមានពណ៌ផ្កាឈូក ហើយកង់របស់វាមានពីរ អញ្ចឹងម៉ូតូមានកង់តែពីរទេ
គឺកង់ខាងមុខមួយ និងកង់ខាងក្រោយមួយ ហើយម៉ូតូរបស់គាត់នៅខាងមុខ
គឺមានចង្កៀងសម្រាប់បំភ្លឺផ្លូវ អញ្ចឹងនៅពេលយប់ ឬក៏នៅពេលព្រឹ្រ នៅពេលមេឃភ្លៀង
គឺយើងអាចបើកចង្កៀងនោះ ដើម្បីឲ្យអំពូលភ្លឺ ដើម្បីបំភ្លឺផ្លូវបាន ឬក៏នៅពេលមេឃភ្លៀង
គឺនៅពេលដែលយើងមើលអ្វីមិនឃើញ យើងអាចបើកភ្លើង ដើម្បីឲ្យអ្នកនៅខាងមុខដឹងថាមានម៉ូតូ
ឬក៏យើងមើលដើម្បីឲ្យដឹងថា នៅខាងមុខមានគ្រលុក ឬក៏មានឧបសគ្គផ្សេងៗ
អញ្ចឹងចង្កៀងម៉ូតូគឺមានពីរ មួយនៅខាងមុខ និងមួយទៀតនៅខាងក្រោយ
ដែលចង្កៀងនៅខាងមុខគឺមានពណ៌រាងលឿងបន្តិច
ចំណែកចង្កៀងនៅខាងក្រោយគឺមានពណ៌ក្រហម យើងឃើញថា
ម៉ូតូរបស់គាត់ដាក់កញ្ចក់មើលក្រោយផងដែរ
អញ្ចឹងគ្រប់ម៉ូតូទាំងអស់គឺត្រូវតែដាក់កញ្ចក់មើលក្រោយ ព្រោះថានៅពេលដែលយើងជិះម៉ូតូ
ប្រសិនបើយើងមិនដាក់កញ្ចក់មើលក្រោយនោះទេ គឺយើងនឹងពិបាកជិះ
ដោយសារតែយើងត្រូវងាកក្រោយមើលថាតើមាននរណានៅពីក្រោយឬអត់
ក៏ប៉ុន្តែប្រសិនបើយើងដាក់កញ្ចក់មើលក្រោយ គឺយើងគ្រាន់តែក្រឡេកមើលទៅកញ្ចក់បន្តិច
យើងនឹងដឹងថាមានអ្នកណានៅខាងក្រោយហើយ មួយវិញទៀតគឺ
ប្រសិនបើយើងមិនដាក់កញ្ចក់មើលក្រោយទេ គឺមិន មិនត្រឹមត្រូវនោះទេ
ព្រោះគឺខុសនឹងច្បាប់ចរាចរណ៍ អញ្ចឹងប៉ូលិសអាចពិន័យយើងបាន
ព្រោះតែយើងមិនដាក់កញ្ចក់មើលក្រោយ ហើយនារីម្នាក់នោះ គាត់ជិះម៉ូតូ
គឺគាត់ពាក់មួកសុវត្ថិភាពផងដែរ អញ្ចឹងគឺនារីម្នាក់នោះ យើងឃើញថា
គាត់គោរពច្បាប់ចរាចរណ៍ណាស់ ដោយគាត់ដាក់កញ្ចក់ម៉ូតូ ហើយគាត់ពាក់មួកសុវត្ថិភាពផងដែរ
អញ្ចឹងនៅពេលដែលយើងជិះម៉ូតូ យើងត្រូវតែពាក់មួកសុវត្ថិភាព
ព្រោះថាប្រសិនបើយើងមិនពាក់នោះទេ នៅពេលដែលយើងដួល
អញ្ចឹងយើងអាចមានគ្រោះថ្នាក់ផ្សេងៗ ដែលប៉ះពាល់ដល់ក្បាល ដូចជាដួលបែកក្បាល
ឬក៏ពកក្បាលជាដើម អញ្ចឹងប្រសិនបើយើងពាក់មួកសុវត្ថិភាព
គឺយើងនឹងមិនមានបញ្ហាក្បាលកើតឡើងនោះទេ ម្យ៉ាងវិញទៀត
ប្រសិនបើមិនពាក់មួកសុវត្ថិភាពនៅពេលជិះម៉ូតូ គឺប៉ូលិសនឹងធ្វើការពិន័យយើងដូចគ្នា
ដូចដែលយើងជិះម៉ូតូមិនដាក់កញ្ចក់ដែរ។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ បន្ទាប់ពីគាត់ជិះម៉ូតូបានបន្តិចក្រោយមក
គឺមកដល់រោងភាពយន្ត ឬក៏រោងកុន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលគាត់បានណាត់គ្នាជាមួយនឹងមិត្តភក្តិរបស់គាត់តាមរយៈឆាត អញ្ចឹងការដែលយើងផ្ញើសារ ឬក៏ខលដើម្បីចង់ជួបនរណាម្នាក់ យើងហៅថាការណាត់ជួប អញ្ចឹងអម្បាញ់មិញគឺគាត់បានណាត់ជួបជាមួយនឹងមិត្តភក្តិរបស់គាត់នៅក្នុងរោងភាពយន្ត ដូច្នេះហើយទើបគាត់ជិះម៉ូតូមកកាន់រោងភាពយន្ត អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា គាត់មកដល់រោងភាពយន្តមួយ រោងភាពយន្តមួយ ហើយគាត់បានជួបនឹងមិត្តភក្តិរបស់គាត់ យើងឃើញមិត្តភក្តិរបស់គាត់គឺមានអាយុប្រហាក់ប្រហែលនឹងគាត់ដែរ គឺមានអាយុប្រហែលជា ២៥ ឆ្នាំ ប៉ុន្តែមិត្តភក្តិរបស់គាត់គឺរាងធាត់ជាងគាត់បន្តិច អញ្ចឹងនារីម្នាក់នោះ គឺមានរាងស្គម ហើយមិត្តភក្តិរបស់គាត់គឺមានរាងធាត់ អញ្ចឹងគាត់មានរាងធាត់ ហើយមិត្តភក្តិរបស់គាត់គឺទម្លាក់សក់ចុះក្រោម បានន័យថាសក់គាត់អត់ចងទេ អញ្ចឹងសក់គាត់នៅត្រឹមស្មា ហើយគាត់ទម្លាក់ចុះ ដែលនារីម្នាក់នោះ គាត់ពាក់អាវលឿងដៃខ្លី ហើយស្លៀកសំពត់ពណ៌ខ្មៅ អញ្ចឹងគាត់ស្លៀកសំពត់ពណ៌ខ្មៅខ្លី ហើយនារីម្នាក់នោះ គាត់បានលើកដៃមួយចំហៀងឡើងលើ ឬក៏ម្ខាងឡើងលើ ដើម្បីជាសញ្ញាហៅមិត្តភក្តិរបស់គាត់ អញ្ចឹងនារីម្នាក់ដែលមានវ័យ ២៥ ឆ្នាំ ដែលពាក់អាវពណ៌ខៀវនោះ គាត់ក៏បានលើកដៃម្ខាងឡើងលើដែរ ដើម្បីជាសញ្ញាថាពួកគេបានជួបគ្នា ឬក៏ពួកគេបានឃើញគ្នាហើយ អញ្ចឹងពួកគេទាំងពីរនាក់ គឺបានមកដល់រោងកុន ឬរោងភាពយន្តទាំងពីរនាក់តែម្តង ដោយយើងឃើញនៅលើជញ្ជាំង យើងឃើញមានបដាផ្សព្វផ្សាយ អញ្ចឹងបានន័យថាមានក្រដាសលិខិតផ្សព្វផ្សាយដែលបិទនៅលើជញ្ជាំង ដែលគេផ្សព្វផ្សាយអំពីរឿង ឬក៏ដែលគេផ្សព្វផ្សាយអំពីសាច់រឿងដែលគេនឹងបញ្ចាំងនៅក្នុងរោងកុន អញ្ចឹងពេលខ្លះគេបានបិទបដាផ្សាយពាណិជ្ជកម្មនៅលើជញ្ជាំង ដើម្បីឲ្យអ្នក[ទៅ]មើលដឹងថា តើគេមានបញ្ចាំងរឿងអ្វីខ្លះ ដូចនៅក្នុងរូបភាពនេះ យើងឃើញមានបដាពីរនៅលើជញ្ជាំង ដែលកំពុងតែផ្សាយអំពីរឿងដែលគេនឹងបញ្ចាំង។

ចូលដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា ពួកគេទាំងពីរនាក់ក៏បានមកទិញសំបុត្រដើម្បីមើលរឿង អញ្ចឹងជាទូទៅនៅពេលដែលយើងទៅមើលកុននៅក្នុងរោងភាពយន្ត ឬក៏នៅក្នុងរោងកុន យើងត្រូវតែទិញសំបុត្រជាមុនសិន ដោយសំបុត្រគឺយើងអាចជ្រើសរើសបាន ថាយើងចង់អង្គុយកៅអីណា ដូចជានៅក្នុងរោងកុនគឺមានកៅអីច្រើន ហើយកៅអីជាច្រើនជួរពីជិតផ្ទាំងបញ្ចាំងរហូតទៅដល់ខាងក្រោយ អញ្ចឹងជាទូទៅអ្នកដែលទៅមើលកុនទាំងអស់គឺគាត់ចូលចិត្តទិញកៅអីនៅកណ្តាល ព្រោះថាកៅអីនៅកណ្តាលគឺងាយស្រួលមើល បានន័យថាគាត់មើលបានស្រួល ដោយមិនពិបាក មិនឆ្ងាយពេក ឬក៏មិនជិតពេក ចំណែកឯកៅអីខាងមុខគឺរាងពិបាកមើលបន្តិច

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែវាកៀកទៅនឹងផ្ទាំងបញ្ចាំងកុនពេក អញ្ចឹងធ្វើឲ្យយើងងើយឡើងលើ
ពិបាក[ហើយ]រាងរោយកបន្តិច ម្យ៉ាងវិញទៀតគឺរូបភាពនៅក្នុងកុនគឺធំៗ
ដូច្នេះប្រសិនបើយើងអង្គុយមើលជិតពេក គឺអាចធ្វើឲ្យយើងវិលមុខបាន
អញ្ចឹងហើយទើបគេចូលចិត្តមើលកៅអីកណ្ដាល ហើយម្យ៉ាងវិញទៀត
ប្រសិនបើយើងអង្គុយនៅកៅអីខាងក្រោយ គឺមានការពិបាកមើលបន្តិច
ដោយសារតែកៅអីខាងក្រោយគឺឆ្ងាយ អញ្ចឹងវាធ្វើឲ្យយើងពិបាកមើល
ប្រសិនបើយើងអង្គុយនៅកៅអីខាងក្រោយ ដូច្នេះហើយនារីពីរនាក់នេះ
គាត់ប្រហែលជាទិញកៅអីណាមួយដែលគាត់ចង់អង្គុយ ដែលជាកៅអីខាងមុខ កៅអីកណ្ដាល
ឬក៏កៅអីខាងក្រោយជាដើម ហើយចំពោះសំបុត្រកុន គឺយើងមិនចាំបាច់ទៅទិញផ្ទាល់ក៏បានដែរ
ព្រោះឥឡូវនេះគឺយើងអាចទិញតាមរយៈអ៊ីនធឺណិត ឬក៏[យើង]អាចខលទៅកក់បាន
អញ្ចឹងនៅពេលដែលយើងចង់ទៅមើលកុន យើងគ្រាន់តែចូលទៅកាន់វេបសាយ
ឬក៏ទៅកាន់គេហទំព័ររបស់រោងកុននោះ យើងអាចទិញសំបុត្រតាមរយៈអ៊ីនធឺណិតបាន
អញ្ចឹងយើងគ្រាន់តែចូលទៅធ្វើតាមការណែនាំរបស់វេបសាយនោះ
អញ្ចឹងយើងអាចទិញសំបុត្របានដោយងាយស្រួល
ដោយយើងមិនចាំបាច់ទៅទិញនៅក្នុងរោងកុននោះទេ អញ្ចឹងប៉ុន្តែនារីពីរនាក់នេះ
គឺគាត់ពុំបានទិញតាមអ៊ីនធឺណិតទេ អញ្ចឹងគាត់បានមកដល់រោងកុន ដើម្បីទិញសំបុត្រកុនតែម្ដង
អញ្ចឹងយើងឃើញថានៅក្នុងរូបភាពនេះគឺគាត់ទិញសំបុត្រកុនចំនួនពីរសន្លឹក គឺសម្រាប់គាត់មួយ
និងសម្រាប់មិត្តភក្តិរបស់គាត់មួយ។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីពួកគេទិញសំបុត្រកុនរួចហើយ
ពួកគេក៏បានមកកាន់កន្លែងលក់ចំណីម្ដង ដែលជាទូទៅនៅក្នុងរោងកុនគឺតែងតែមានកន្លែងលក់ចំណី
ដែលលក់ចំណីមានដូចជាពោតលីង មានដូចជាសូកូឡា មានដូចជានំប្រៃ មានដូចជានំកញ្ចប់ជាដើម
អញ្ចឹងពួកគេនៅក្នុងរូបភាពនេះ គេបានទិញជាពោតលីង
ដើម្បីអង្គុយញ៉ាំនៅពេលដែលពួកគេមើលរឿង ឬក៏មើលភាពយន្ត
អញ្ចឹងពោតលីងដែលលក់នៅក្នុងរោងភាពយន្ត ឬក៏នៅក្នុងរោងកុន គេតែងតែខ្ចប់
ឬក៏ច្រកចូលទៅក្នុងប្រអប់ក្រដាសៗមួយ អញ្ចឹងដូចជានៅក្នុងរូបភាពនេះជាដើម
គឺគេបានច្រកពោតលីងនោះចូលទៅក្នុងប្រអប់ក្រដាស
ដោយយើងឃើញអ្នកលក់ពោតលីងគឺនៅខាងក្នុង អ្នកលក់ពោតលីងនៅខាងក្នុង
ឬក៏នៅខាងក្រោយតុមួយ អញ្ចឹងគាត់បានពាក់អាវពណ៌លឿង ឬក៏ពណ៌ទឹកក្រូច
អញ្ចឹងគាត់បានពាក់អាវពណ៌ទឹកក្រូច ហើយមានពាក់មួកមួយផងដែរ អញ្ចឹងមួកគាត់គឺជាមួកចុងភៅ
បានន័យថាគេពាក់ដើម្បីការពារអនាម័យ កុំឲ្យមានសក់ ឬក៏កុំឲ្យមានធូលីដែលនៅលើក្បាល

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជ្រុះចូលទៅក្នុងចំណីអាហារ
អញ្ចឹងគេពាក់ម្មួកមួយដើម្បីការពារកុំឲ្យមានសក់របស់គេជ្រុះទៅចូលទៅក្នុងចំណី
ហើយគេបានពាក់អៀមផងដែរ អញ្ចឹងអៀមក្រណាត់មួយនេះ
គឺគេពាក់ដើម្បីកុំឲ្យប្រឡាក់សម្លៀកបំពាក់ ឬក៏ឯកសណ្ឋានរបស់គេ នៅពេលដែលគេដួសចំណី
ឬក៏ដួសនំនោះចេញមកខាងក្រៅ អញ្ចឹងនៅក្នុងរូបភាពនេះគឺអ្នកលក់គាត់បានប្រគល់នំមួយកញ្ចប់
ឬក៏ប្រគល់ពោតលីងមួយកញ្ចប់ទៅឲ្យនារីពីរនាក់នោះ ដែលតាមការកុម្ម៉ង់ទិញរបស់នារីពីរនាក់នោះ
សម្រាប់យកទៅញ៉ាំនៅពេលដែលពួកគេមើលរឿង ឬក៏មើលភាពយន្តនៅក្នុងរោងកុន។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ បន្ទាប់ពីពួកគេទិញពោតលីង ឬក៏ពោត
ពួកគេទិញពោតលីងមួយកញ្ចប់រួចរាល់ហើយ
អញ្ចឹងពួកគេទាំងពីរនាក់ទិញពោតលីងតែមួយកញ្ចប់នោះទេ ព្រោះពួកគេទិញពោតលីងមួយកញ្ចប់ធំ
អញ្ចឹងពោតលីងមួយកញ្ចប់ធំ គឺពួកគេអាចញ៉ាំបានទាំងពីរនាក់តែម្តង
ហើយបន្ទាប់មកពួកគេក៏បានទិញភេសជ្ជៈ អញ្ចឹងពួកគេបានហៅភេសជ្ជៈពីរដប
ដែលភេសជ្ជៈមានដូចជាកូកាកូឡា មានដូចជា Sprite ដូចជា Fanta
ឬក៏មានភេសជ្ជៈជាច្រើនផ្សេងទៀតដែលលក់នៅក្នុងរោងកុន
អញ្ចឹងប្រសិនបើយើងចង់ញ៉ាំភេសជ្ជៈអ្វី យើងគ្រាន់តែប្រាប់ទៅដល់អ្នកលក់
នោះអ្នកលក់នឹងយកភេសជ្ជៈនោះមកឲ្យយើងដាក់ជាពុំខាន ដូចនៅក្នុងរូបភាពនេះ នារីពីរនាក់នោះ
គាត់បានកុម្ម៉ង់ដូចជាកូកាកូឡាចំនួនពីរដប អញ្ចឹងគាត់ប្រាប់ទៅអ្នកលក់ថា
គាត់ត្រូវការកូកាកូឡាចំនួនពីរដបទៀត
ដូច្នេះហើយទើបអ្នកលក់គាត់ប្រគល់កូកាកូឡាពីរដប់ទៅឲ្យនារីទាំងពីរនាក់
ដោយកូកាកូឡាទាំងពីរដបនោះ គឺមានដាក់បំពង់បឺត ឬក៏ទុយោ ចូលទៅក្នុងដបនោះផងដែរ
ដើម្បីឲ្យពួកគេទាំងពីរនាក់ងាយស្រួលបឺតទឹកកូកាចេញពីដបនោះ
អញ្ចឹងពួកគេមិនញ៉ាំផ្ទាល់ដបនោះទេ ពួកគេប្រើបំពង់បឺត ឬក៏ទុយោ ដើម្បីបឺតកូកាចេញពីដប។

បន្ទាប់មកចូលដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា
បន្ទាប់ពីពួកគេទិញចំណីរួចរាល់ហើយ អញ្ចឹងមុនពេលដែលគេចូលទៅក្នុងរោងកុន
គេត្រូវទិញចំណីញ៉ាំជាមុនសិន ដើម្បីញ៉ាំនៅពេលដែលគេកំពុងមើលរឿង
អញ្ចឹងបន្ទាប់ពីគេទិញចំណីរួចរាល់ហើយ ពួកគេក៏បានដើរចូលមកក្នុងកន្លែងបញ្ចាំងរឿង
អញ្ចឹងមុននឹងគេអាចចូលបាន គេត្រូវយកសំបុត្រទៅឲ្យអ្នកត្រួតពិនិត្យសំបុត្រសិន
អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងឃើញមានអ្នកត្រួតសំបុត្រ
ត្រួតពិនិត្យសំបុត្រកំពុងតែឈរនៅខាងមុខទ្វារ ដើម្បីចូលទៅមើលទ្វារចូលទៅកន្លែងបញ្ចាំងរឿង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងអ្នកពិនិត្យសំបុត្រ គាត់ឈរនៅខាងមុខទ្វារ ហើយគាត់ក៏កាន់យកសំបុត្រពីនារីពីរនាក់នោះ
ដោយនារីពីរនាក់នោះ គាត់បានប្រគល់សំបុត្រចំនួនពីរសន្លឹកទៅឲ្យអ្នកពិនិត្យសំបុត្រ
ហើយអ្នកពិនិត្យសំបុត្រ គាត់ក៏បានត្រួតពិនិត្យសំបុត្រនោះថាត្រឹមត្រូវដែរឬទេ
អញ្ចឹងយើងឃើញអ្នកត្រួតពិនិត្យសំបុត្រនោះ គឺគាត់ស្លៀកខោជើងវែងពណ៌ស អាវពណ៌ស
ហើយមានពាក់មួកមួយផងដែរ អញ្ចឹងគាត់មានពាក់មួកមួយដូចគ្នា ដូចអ្នកលក់ដែរ
ក៏ប៉ុន្តែមួកនោះគឺជាមួកសញ្ញានោះសម្គាល់ថា គាត់ជាអ្នកត្រួតពិនិត្យសំបុត្រ
ហើយនៅដៃរបស់គាត់ម្ខាង គឺមានកាន់ពិលចំនួនមួយ អញ្ចឹងគាត់កាន់ពិល
ដើម្បីបំភ្លឺនៅពេលដែលភ្ញៀវចូលទៅក្នុងកន្លែងបញ្ចាំងកុនគឺងងឹត
ដូច្នេះគាត់ត្រូវកាន់ពិលដើម្បីបញ្ចាំងឲ្យភ្ញៀវដើរទៅត្រូវកន្លែងរបស់គេដែលត្រូវអង្គុយ
អញ្ចឹងនៅក្នុងដៃរបស់អ្នកត្រួតពិនិត្យសំបុត្រ គឺមានពិលចំនួនមួយដើម្បីបញ្ចាំង
ហើយយើងឃើញនៅក្នុងដៃរបស់នារីពីរនាក់នោះ គឺកំពុងតែកាន់ទឹកក្រូចកូកាម្នាក់មួយដបៗ
ហើយនៅក្នុងដៃនារីដែលពាក់អាវលឿង គឺមានពោតលីងចំនួនមួយកញ្ចប់ផងដែរ
ដែលគេបានទិញអម្បាញ់មិញ អញ្ចឹងពួកគេយកកូកានិងពោតលីង
ដើម្បីចូលទៅញ៉ាំនៅក្នុងពេលដែលគេមើលរឿងកុន ហើយមុនពេលដែលគេចូល
គឺគេហុចសំបុត្រទៅឲ្យអ្នកពិនិត្យសំបុត្រ ដើម្បីត្រួតពិនិត្យថាត្រឹមត្រូវដែរឬទេ
ហើយគេត្រូវអង្គុយនៅកៅអីលេខប៉ុន្មាន។

បន្ទាប់មកមកដល់រូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីត្រួតពិនិត្យសំបុត្ររួចរាល់ហើយ បន្ទាប់ពីត្រួតពិនិត្យសំបុត្ររួចរាល់ហើយ ពួកគេទាំងពីរនាក់
ក៏បានដើរចូលមកក្នុងកន្លែងអង្គុយ អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថា
មានមនុស្សជាច្រើនកំពុងតែអង្គុយមើលកុន អញ្ចឹងបានន័យថានារីពីរនាក់នោះ
គាត់បានមកក្រោយគេ អញ្ចឹងបានន័យថាមានអ្នកចូលមើលជាច្រើនរួចរាល់មកហើយ
ដែលបានចូលមកមុននារីម្នាក់នោះ ដោយយើងឃើញមានកៅអីចំនួនបីជួរ
នៅក្នុងនោះគឺជួរទីមួយគឺមាននារីម្នាក់និងមានបុរសពីរនាក់
ដោយមានបុរសដែលអង្គុយនៅខាងគេបំផុត គឺគាត់សក់ទំពែក
អញ្ចឹងគាត់អត់មានសក់នៅលើក្បាលនោះទេ ហើយបុរសដែលអង្គុយកណ្តាល
គឺមានរាងវយក្មេងបន្តិច ចំណែកឯនៅខាងគេម្ខាងទៀតគឺមាននារីម្នាក់ដែលអង្គុយមើលដែរ
អញ្ចឹងបានន័យថាពួកគេទាំងអស់គ្នាកំពុងតែមកមើលកុនដូចគ្នា ចំណែកឯជួរទី ២
គឺយើងឃើញមានសុទ្ធតែនារីពីរនាក់ គឺ[មាន]នារីចំនួនពីរនាក់កំពុងតែអង្គុយមើលកុន
ហើយមានបុរសចំនួនម្នាក់ អញ្ចឹងនារីពីរនាក់នោះគឺកៅអីគាត់នៅជួរទី ៣
អញ្ចឹងគាត់ដើរសំដៅទៅកាន់ជួរទី ៣ ដើម្បីអង្គុយនៅកន្លែងរបស់គាត់ដែលគាត់បានទិញសំបុត្រ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថាគាត់ទិញសំបុត្រដើម្បីអង្គុយនៅជួរទី ៣ ដូច្នេះហើយទើបជួរទី ៣ ពុំមាននរណាអង្គុយ អញ្ចឹងគាត់បានកាន់ទឹកក្រូច និងកាន់ popcorn ឬក៏កាន់ពោតលីងរបស់គាត់មកកាន់កៅអីជួរទីបីដើម្បីអង្គុយមើលកុន។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្ទាប់ពីពួកគេដើរមកដល់កៅអីអង្គុយហើយ ពួកគេក៏បានចូលទៅកាន់កន្លែងរបស់គេដើម្បីអង្គុយ អញ្ចឹងគេមើលទៅលើសំបុត្ររបស់គេថាគេ[កាន់]អង្គុយនៅក្នុងកៅអីលេខប៉ុន្មាន អញ្ចឹងជាទូទៅកៅអីនៅក្នុងរោងកុនគឺតែងតែមានដាក់លេខ ដាក់លេខសម្គាល់ ឬក៏ដាក់អក្សរសម្គាល់ដើម្បីឲ្យដឹងថា តើអ្នកមើលមួយៗ គឺគេត្រូវអង្គុយនៅកៅអីលេខប៉ុន្មាន ដើម្បីកុំឲ្យមានការជណ្ដើមគ្នា អញ្ចឹងគេតែងតែកំណត់លេខ ដើម្បី នៅក្នុងសំបុត្រផងនិងនៅលើកៅអីផង ដើម្បីឲ្យអ្នកមើល ឬក៏ទស្សនិកជនងាយស្រួលក្នុងការស្វែងរកកៅអីដើម្បីអង្គុយ អញ្ចឹងពួកគេទាំងពីរនាក់នៅក្នុងរូបភាពទី ៩ នេះ គឺបានរកឃើញកៅអីដើម្បីអង្គុយរួចរាល់ហើយ អញ្ចឹងពួកគេក៏បានចូលមកកាន់កៅអីអង្គុយរបស់គេ ហើយគេបានដាក់ដបកូកា ឬក៏ដបទឹកក្រូចរបស់គេទៅកាន់កន្លែងសម្រាប់ដាក់ដបទឹកក្រូច អញ្ចឹងជាទូទៅនៅក្នុងរោងភាពយន្ត ឬក៏ក្នុងរោងកុន កៅអីរបស់វាតែងតែមានកន្លែងសម្រាប់ដាក់ចំណី អញ្ចឹងគេមានកន្លែងសម្រាប់ដាក់ទឹកក្រូច គេមានកន្លែងសម្រាប់ដាក់ភេសជ្ជៈផ្សេងៗផងដែរ ដូចជាជាក់ស្ដែងនៅក្នុងរូបភាពទី ៩ គឺពួកគេទាំងពីរនាក់បានដាក់ដបទឹកក្រូចទៅកាន់បង្កាន់ដៃកៅអី ដែលជាកន្លែងសម្រាប់ដាក់ដបទឹកក្រូច អញ្ចឹងពួកគេបានដាក់ដបទឹកក្រូចចូលទៅក្នុងកន្លែងដាក់ដបទឹកក្រូចដែលនៅលើបង្កាន់ដៃ ចំណែកឯពោតលីងគឺពុំមានកន្លែងដាក់នោះទេ អញ្ចឹងគេក៏បានអង្គុយឱបពោតលីង អញ្ចឹងនារីពាក់អាវលឿង ដែលពាក់អាវលឿងដៃខ្លី សំពត់ពណ៌ខ្មៅជើងខ្លីនោះ គឺគាត់កំពុងតែអង្គុយឱបពោតលីង ប៉ុន្តែដបទឹកក្រូចរបស់គាត់គឺដាក់នៅលើបង្កាន់ដៃកៅអី ហើយពួកគេទាំងពីរនាក់ក៏បានអង្គុយមើលកុន។

បន្ទាប់មករូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីពួកគេចូលទៅក្នុងរោងកុនបានបន្តិចក្រោយមក គេក៏ចាប់ផ្ដើមបញ្ចាំងវីដេអូមួយចំនួនទៅលើផ្ទាំងបញ្ចាំងរូបភាព អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា មុននឹងសាច់រឿងចាប់ផ្ដើម គឺមានការផ្សាយពាណិជ្ជកម្មជាមុនសិន អញ្ចឹងជាទូទៅនៅពេលដែលយើងទៅមើលកុន មុននឹងចាប់ផ្ដើមលេងរឿង គឺគេតែងតែផ្សាយពាណិជ្ជកម្ម ដែលនៅក្នុងរូបភាពនេះ គឺយើងមើលទៅគឺ គឺជារូបភាពឡាន គឺគេកំពុងតែបញ្ចាំងរូបភាពឡាន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថាគេកំពុងតែផ្សាយពាណិជ្ជកម្មអំពីឡាន ឬក៏ផ្សាយពាណិជ្ជកម្មអំពីការលក់ឡាន ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺមានឡានពណ៌ទឹកក្រូចចំនួនមួយ កំពុងតែបើកនៅតាមផ្លូវ អញ្ចឹងឡានពណ៌ទឹកក្រូចកំពុងតែបើកនៅតាមផ្លូវ ដោយមាន នៅក្បែរនោះយើងឃើញមានរូបសញ្ញាដុល្លារ អញ្ចឹងបានន័យថាឡាននេះគឺគេកំពុងតែលក់ អញ្ចឹងនៅក្នុងរូបភាពនេះ គឺ[ជា]ការនិយាយអំពីការផ្សាយពាណិជ្ជកម្មលក់ឡានទៅដល់ទស្សនិកជន ព្រោះថានៅក្នុងរោងកុនគឺមានទស្សនិកជនច្រើន អញ្ចឹងប្រសិនបើគេផ្សាយពាណិជ្ជកម្មនៅក្នុងរោងកុន គឺអាចធ្វើឲ្យទស្សនិកជនជាច្រើន គាត់អាចចាប់អារម្មណ៍ទៅលើពាណិជ្ជកម្មរបស់គាត់ អញ្ចឹងនៅពេលដែលគាត់ផ្សាយពាណិជ្ជកម្មលក់ឡាននៅក្នុងរោងកុន គឺអាចធ្វើឲ្យមានមនុស្សជាច្រើនដឹងថាឡានមួយនោះកំពុងតែលក់ ហើយអាចដឹងថា តើឡាននោះមានលក្ខណៈពិសេសអ្វីខ្លះ ដែលទស្សនិកជនជាច្រើនគាត់អាចដឹង ដូច្នេះហើយទើបគេធ្វើការផ្សាយពាណិជ្ជកម្មនៅក្នុងរោងភាពយន្ត មុននឹងគេចាប់ផ្ដើមបញ្ចាំងរឿងដែលយើងចង់មើល។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ បន្ទាប់ពីសាច់រឿង ឬក៏ពាណិជ្ជកម្មបានបញ្ចប់ អញ្ចឹងមុននឹងចូលសាច់រឿង គេផ្សាយពាណិជ្ជកម្មមួយទៅពីរជាមុនសិន អញ្ចឹងគេផ្សាយពាណិជ្ជកម្មមួយទៅពីរ ពាណិជ្ជកម្ម បន្ទាប់មកក៏គេចូលសាច់រឿង អញ្ចឹងនៅក្នុងរូបភាពទី ១១ គឺសាច់រឿងបានចាប់ផ្ដើម ដូច្នេះហើយទស្សនិកជនទាំងអស់ ក៏ចាប់ផ្ដើមបិទសំឡេងទូរស័ព្ទ ហើយក៏បិទសំឡេងរោទ៍ អញ្ចឹងនៅក្នុងរោងកុនគឺគេពុំអនុញ្ញាតឲ្យយើងបើកសំឡេងរោទ៍ទូរស័ព្ទនោះទេ អញ្ចឹងប្រសិនបើយើងមានទូរស័ព្ទ យើងត្រូវតែដាក់ញ័រ គឺយើងបិទសំឡេង មិនឲ្យឮសំឡេងនោះទេ គឺយើងត្រូវតែដាក់ញ័រ ដើម្បីកុំឲ្យរំខានដល់អ្នកដទៃ ព្រោះថាគេទៅមើលរឿង គឺគេត្រូវការស្ងប់ស្ងាត់ អញ្ចឹងប្រសិនបើទូរស័ព្ទរបស់យើងរោទ៍ ឬក៏ទូរស័ព្ទរបស់យើងមានសំឡេងរំខាន វានឹងធ្វើឲ្យមានការរំខានទៅដល់ទស្សនិកជន ឬក៏អ្នកមើលដទៃទៀត ដូច្នេះហើយនៅក្នុងរោងភាពយន្ត គឺគេមិនអនុញ្ញាតឲ្យយើងដាក់សំឡេងរោទ៍ទូរស័ព្ទនោះទេ ប្រសិនបើមានទូរស័ព្ទយើងត្រូវតែដាក់ញ័រ អញ្ចឹងនៅក្នុងរូបភាពនេះ គឺសាច់រឿងបានចាប់ផ្ដើម អញ្ចឹងគឺចាប់ផ្ដើមបញ្ចាំងរឿងហើយ ដូច្នេះហើយទស្សនិកជនទាំងអស់ក៏បានបិទទូរស័ព្ទ ឬក៏បិទសំឡេងទូរស័ព្ទទាំងអស់គ្នាដើម្បីមើលរឿង ហើយដើម្បីកុំឲ្យរំខានដល់អ្នកដទៃ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា រឿងដែលគេកំពុងតែមើល គឺជារឿងមនោសញ្ចេតនា អញ្ចឹងរឿងស្នេហា ឬយើងអាចហៅថារឿងមនោសញ្ចេតនា ដែលរឿងនេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺមិនមានការវ៉ៃវាយគ្នា ឬក៏វាយតប់នោះទេ អញ្ចឹងឈុតឆាកនៅក្នុងរឿងនេះ គឺពុំមានឈុតវាយគ្នា ឬក៏បាញ់ប្រហារនោះទេ គឺជារឿងមនោសញ្ចេតនា អញ្ចឹងបានន័យថា គេនិយាយអំពីស្នេហារវាងមនុស្សប្រុសនិងមនុស្សស្រី ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១២ យើងឃើញថា មានបុរសម្នាក់ គាត់កំពុងតែឈរនិយាយជាមួយនឹងមិត្តស្រីរបស់គាត់ ដែលបុរសម្នាក់នោះ គាត់ពាក់អាវពណ៌ស្វាយ សក់ខ្លី ហើយគាត់ជាបុរសមានវ័យក្មេង អាយុគាត់ប្រហែល ២០ ឆ្នាំ ដែលគាត់កំពុងតែឈរជាមួយនឹងមិត្តស្រីរបស់គាត់និយាយគ្នា ដែលមិត្តស្រីរបស់គាត់មានសក់វែងចងទៅក្រោយ ហើយពាក់អាវពណ៌ទឹកក្រូច អញ្ចឹងពួកគេទាំងពីរនាក់កំពុងតែសម្តែងរឿង ឬក៏បានន័យថាពួកគេទាំងពីរនាក់ កំពុងតែលេងរឿង ហើយពួកគេគឺលេងរឿងស្នេហា អញ្ចឹងអ្នកសម្តែងរឿងដែលនៅក្នុងកុន យើងហៅថាតួកុន ឬក៏តារាភាពយន្ត អញ្ចឹងពួកគេទាំងពីរនាក់គឺជាតារាភាពយន្ត ឬក៏តួកុន ដែលពួកគេបានសម្តែងភាពយន្ត ឬក៏សម្តែងរឿង ដើម្បីបញ្ចាំងនៅក្នុងកុន ដូច្នេះហើយទើបយើងហៅថាតួកុន ឬក៏តារាភាពយន្ត អញ្ចឹងពាក្យថាតារាគឺបានន័យថាអ្នកសម្តែង អញ្ចឹងយើងអាចហៅបានពីរ តារា គឺផ្កាយនៅលើមេឃ អញ្ចឹងពេលខ្លះយើងហៅផ្កាយក៏ថាតារាដែរ ហើយចំពោះអ្នកសម្តែងភាពយន្ត ឬក៏សម្តែងរឿង ឬក៏សម្តែងកុន ក៏យើងហៅថាតារាដែរ អញ្ចឹងយើងអាចហៅថា ពួកគេគឺជាតារាភាពយន្ត ឬក៏តួកុន ដែលពួកគេកំពុងតែសម្តែងរឿង។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់ពីលេងរឿងបានបន្តិចក្រោយមក គឺមួយសន្ទុះក្រោយមក គឺរឿងក៏បានចប់ អញ្ចឹងជាទូទៅរឿងដែលបញ្ចាំងនៅក្នុងកុន គឺជាធម្មតាគឺមានរយៈពេលប្រហែលជា ៦០ នាទីទៅ ៩០ នាទី អញ្ចឹង ៦០ នាទីយើងហៅថា ១ ម៉ោង ចំណែកឯ ៩០ នាទី យើងអាចនិយាយបានថា ១ ម៉ោងកន្លះ ព្រោះថាមួយម៉ោងមាន ៦០ នាទី ចំណែកឯ ៩០ នាទី គឺមាន ៦០ នាទីបូកនឹង ៣០ នាទី ដូច្នេះហើយយើងអាចហៅថាមួយម៉ោងកន្លះ អញ្ចឹងជាទូទៅនៅរោងភាពយន្តគេបញ្ចាំងរឿងពី ៦០ នាទីទៅ ៩០ នាទី បន្ទាប់មក បន្ទាប់ពីពួកគេមើលអស់រយៈពេល ៩០ នាទីមក ភាពយន្តក៏បានបញ្ចប់ អញ្ចឹងរឿងនោះគឺជារឿងស្នេហា ដូច្នេះហើយទើបយើងឃើញថា នៅពេលដែលបញ្ចប់គឺមានលោតអក្សរចេញមកក្រៅ គឺមានអក្សររត់ឡើងលើ ដែលផ្សាយអំពីតួសម្តែង ដែលផ្សាយអំពីអ្នកដឹកនាំរឿង ដែលផ្សាយអំពីអ្នកនិពន្ធជាដើម អញ្ចឹងនៅពេលដែលបញ្ចប់ គេតែងតែបញ្ជាក់អំពីអ្នកនិពន្ធ អ្នកសម្តែង តើជានរណា ហើយអ្នកកាត់ត និងអ្នកបច្ចេកទេសផ្សេងៗនៅក្នុង[រូប]ភាពយន្តនោះដែលជានរណាខ្លះ អញ្ចឹងគេតែងតែដាក់នៅក្នុងពេលដែលចប់សាច់រឿង គឺគេដាក់នៅក្នុងអក្សរដើម្បីរត់ឡើងលើ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺយើងឃើញមានឆ្នេរសមុទ្រ អញ្ចឹងបានន័យថារូបភាព ភាពយន្តនេះគេបញ្ចាំងនេះគឺ បញ្ចប់នៅក្នុងឆ្នេរសមុទ្រ ដែលយើងឃើញមានឆ្នេរសមុទ្រ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងមានទឹកសមុទ្រពណ៌ខៀវ ហើយមានទូកមួយកំពុងតែអណ្តែតនៅលើទឹកសមុទ្រនោះ អញ្ចឹងទូកនោះគឺជាទូកក្តោង ដែលអណ្តែតនៅលើសមុទ្រ ហើយយើងឃើញថា ផ្ទៃមេឃគឺថាស្រឡះល្អណាស់ គឺយើងឃើញថាមានព្រះអាទិត្យកំពុងតែរះ ហើយមានពពកពណ៌សជាច្រើនកំពុងតែរសាត់នៅលើអាកាស អញ្ចឹងរឿងនោះជារឿងស្នេហា ដូច្នេះហើយគេត្រូវតែរករូបភាពណា ឬក៏វីដេអូណា romantic ឬក៏វីដេអូណាដែលធ្វើឲ្យយើងមានអារម្មណ៍មានមនោសញ្ចេតនា ដើម្បីយកមកបញ្ចាំង អញ្ចឹងនៅក្នុងរូបភាពទី ១៣ នេះ គឺភាពយន្តត្រូវបានបញ្ចប់ ដូច្នេះអ្នកមើលទាំងអស់ត្រូវតែក្រោកពីកៅអីដើម្បីចេញក្រៅ។

ចូលមកដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីភាពយន្តចប់ គឺអ្នកមើលទាំងអស់ ឬក៏យើងហៅថាទស្សនិកជន អញ្ចឹងអ្នកមើលភាពយន្ត ឬក៏អ្នកមើលទូរទស្សន៍ អ្នកមើលរឿងផ្សេងៗ យើងហៅថាទស្សនិកជន អញ្ចឹងបន្ទាប់ពីសាច់រឿងចប់ហើយ យើងឃើញថាទស្សនិកជនទាំងអស់ក៏បានក្រោកចេញពីកៅអី ដើម្បីដើរចេញទៅក្រៅរោងកុនវិញ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថាអ្នកមើល ឬក៏ទស្សនិកជនដែលអង្គុយខាងមុខនារីពីរនាក់នោះ គឺបានចេញខាងក្រៅអស់ហើយ អញ្ចឹងនារីពីរនាក់នោះ ក៏បានចេញខាងក្រៅរោងភាពយន្តដែរ គឺចេញខាងក្រៅដូចគ្នា ដូច្នេះហើយពួកគេទាំងពីរនាក់ក៏បានដើរបណ្តើរនិយាយគ្នាបណ្តើរ ដោយពួកគេនិយាយគ្នាអំពីសាច់រឿងដែលគេបានមើលអម្បាញ់មិញថាពិតជាល្អមើលណាស់ អញ្ចឹងពួកគេទាំងពីរនាក់ក៏ដើរបណ្តើរនិយាយបណ្តើរ ដោយនារីពាក់អាវខៀវគាត់ដើរខាងមុខ ហើយនារីដែលពាក់អាវលឿងគាត់ដើរខាងក្រោយ ហើយនារីពាក់អាវខៀវគាត់ដើរបណ្តើរងាកក្រោយបណ្តើរ ដើម្បីនិយាយជាមួយមិត្តភក្តិរបស់គាត់អំពីសាច់រឿងដែលគេបានមើលអម្បាញ់មិញ ព្រោះ[...]សាច់រឿងបានចប់ហើយ ដូច្នេះពួកគេដើរចេញពីក្នុងរោងកុន។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីគេដើរបន្តិចមក ពួកគេបានចេញមកក្រៅរោងកុន ហើយគេបានមកយកម៉ូតូនៅកន្លែងចតម៉ូតូរបស់ពួកគេ អញ្ចឹងយើងឃើញថា ពួកគេបានដើរមកដល់ម៉ូតូរបស់ពួកគេដែលកំពុងតែចត ហើយពួកគេបានលាគ្នាទៅផ្ទះទៅវិញទៅមក អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា នារីដែលពាក់អាវពណ៌លឿង គាត់បានពាក់មួកសុវត្ថិភាពរួចរាល់ហើយដើម្បីជិះម៉ូតូ ដែលម៉ូតូរបស់គាត់គឺមានពណ៌ខៀវ ឬក៏ពណ៌ទឹកសមុទ្រ អញ្ចឹងម៉ូតូរបស់គាត់គឺមានកង់ពីរដូចគ្នា ហើយមានដាក់កញ្ចក់ដូចគ្នា អញ្ចឹងម៉ូតូរបស់គាត់គឺកំពុងតែដាក់ចន្ទល់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បានន័យថាគាត់ពុំទាន់បានយកម៉ូតូរបស់គាត់នោះទេ គឺគាត់គ្រាន់តែពាក់មួកសុវត្ថិភាពជាមុនសិន យើងឃើញថាម៉ូតូរបស់គាត់គឺដាក់ចន្ទល់ ជាធម្មតានៅពេលដែលយើងចតម៉ូតូ យើងត្រូវដាក់ចន្ទល់ ព្រោះថានៅពេលដែលយើងមិនដាក់ចន្ទល់នោះទេ ម៉ូតូយើងអាចដួល ធ្វើឲ្យខូចខាតម៉ូតូ អញ្ចឹងហើយយើងត្រូវដាក់ចន្ទល់ ចន្ទល់ម៉ូតូ ចន្ទល់ម៉ូតូគឺជាដែកសម្រាប់ទប់ម៉ូតូកុំឲ្យដួល អញ្ចឹងនៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះ គាត់ពុំទាន់បានយកម៉ូតូគាត់នោះទេ ព្រោះថាម៉ូតូគាត់នៅដាក់ចន្ទល់នៅឡើយ ចំណែកឯនារីពាក់អាវខៀវវិញ គឺបានន័យថាគាត់កំពុងតែបណ្តើរម៉ូតូ អញ្ចឹងបានន័យថាម៉ូតូរបស់គាត់លែងដាក់ចន្ទល់ហើយ គឺគាត់លើកចន្ទល់ឡើង ហើយគាត់កំពុងតែបណ្តើរ អញ្ចឹងនៅពេលដែលយើងចាប់កាន់ម៉ូតូ ហើយយើងពុំទាន់ជិះ យើងហៅថាបណ្តើរម៉ូតូ អញ្ចឹងយើងដើរបណ្តើរ អូសម៉ូតូទៅខាងមុខបណ្តើរ ឬក៏រុញម៉ូតូទៅខាងមុខបណ្តើរ អញ្ចឹងយើងហៅថាបណ្តើរម៉ូតូ អញ្ចឹងគាត់ទាំងពីរនាក់ពុំទាន់បានជិះម៉ូតូនោះទេ ដែលពួកគាត់កំពុងតែលាគ្នាសិន ដោយនារីដែលពាក់អាវលឿង គាត់បានលើកដៃជាសញ្ញាលាទៅកាន់មិត្តភក្តិរបស់គាត់ ហើយនារីដែលពាក់អាវខៀវ គាត់ក៏បានងាកមកក្រោយ ហើយគាត់ក៏លានិយាយលាគ្នាទៅកាន់មិត្តភក្តិរបស់គាត់ដែរ ប៉ុន្តែគាត់ពុំបានលើកដៃនោះទេ ដោយសារតែដៃរបស់គាត់ជាប់កាន់ម៉ូតូ។

បន្ទាប់មកទៀតចូលដល់រូបភាពទី ១៦ អញ្ចឹងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីគាត់បានលាមិត្តភក្តិរបស់គាត់ចេញពីរោងកុនហើយ នារីដែលពាក់អាវពណ៌ខៀវនោះ គាត់ក៏បានឡើងជិះម៉ូតូរបស់គាត់ អញ្ចឹងគាត់បានជិះម៉ូតូរបស់គាត់ដោយពាក់មួកសុវត្ថិភាព ហើយគាត់បានជិះសំដៅទៅផ្ទះរបស់គាត់វិញ អញ្ចឹងបានន័យថាគាត់កំពុងតែចេញពីរោងកុន ដើម្បីសំដៅទៅផ្ទះវិញបន្ទាប់ពីគាត់មើលរឿងចប់ហើយ ថ្ងៃនេះគាត់ពិតជាសប្បាយរីករាយ ដោយសារតែគាត់បានមើលរឿងជាមួយនឹងមិត្តភក្តិរបស់គាត់ ហើយរឿងគឺជារឿងដែលគាត់កំពុងតែចង់មើល អញ្ចឹងបន្ទាប់ពីគាត់មើលរឿងចប់នៅក្នុងរោងហើយ គាត់ក៏បានឡើងជិះម៉ូតូវិញដើម្បីសំដៅទៅផ្ទះរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញថា បន្ទាប់ពីគាត់ជិះម៉ូតូបានបន្តិចក្រោយមក មួយសន្ទុះក្រោយមក គាត់ក៏បានមកដល់ផ្ទះ អញ្ចឹងគាត់មកដល់ផ្ទះ គាត់ក៏បានអង្គុយនៅលើកៅអីដដែល អញ្ចឹងគាត់បានអង្គុយនៅលើកៅអីរបស់គាត់ ដោយកៅអីរបស់គាត់ដាក់នៅខាងមុខតុមួយ នៅលើតុនោះគឺមានកុំព្យូទ័រមួយ អញ្ចឹងគាត់កំពុងតែផ្ញើសារទៅកាន់មិត្តភក្តិរបស់គាត់ ដែលនៅក្នុងនោះ គាត់បានប្រហែលជានិយាយថា គាត់បានមកដល់ផ្ទះហើយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយគាត់ក៏កំពុងតែចង់គេង អញ្ចឹងគាត់ក៏បានលេងសារទៅកាន់មិត្តភក្តិរបស់គាត់
ដើម្បីបញ្ជាក់ប្រាប់មិត្តភក្តិរបស់គាត់ថា គាត់មកដល់ផ្ទះ
ហើយគាត់ក៏បានប្រាប់ទៅមិត្តភក្តិរបស់គាត់ថាគាត់ចង់ចូលគេង
អញ្ចឹងគាត់ក៏បានសួរទៅកាន់មិត្តភក្តិរបស់គាត់ថាតើមិត្តភក្តិរបស់គាត់ហ្នឹងទៅដល់ផ្ទះហើយឬនៅ
ព្រោះប្រហែលជាគាត់មើលរឿងពេលយប់ ដូច្នេះហើយគឺត្រូវសួរគ្នាទៅវិញទៅមក
ដើម្បីចង់ដឹងថាតើមិត្តភក្តិរបស់គាត់មានសុវត្ថិភាពដែរឬទេ
នៅពេលដែលធ្វើដំណើរតាមផ្លូវមកផ្ទះវិញ ហើយម្យ៉ាងវិញទៀត ដោយសារតែវាជាពេលយប់
ដូច្នេះគាត់អស់កម្លាំងជាខ្លាំង បន្ទាប់ពីគាត់មកពីមើលកុន
ដូច្នេះហើយគាត់ក៏បានផ្ញើសារទៅកាន់ប្រាប់ ទៅប្រាប់មិត្តភក្តិរបស់គាត់ថា
គាត់នឹងចូលគេងបន្តិចទៀតនេះ ដោយយើងឃើញនៅក្នុងរូបភាពនេះ
គឺគាត់និយាយអំពីគ្រែគេងផ្ញើសារទៅមិត្តភក្តិរបស់គាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.